ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ០៥៤ MOC / M 2003

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពី

## ការដាក់អោយដេញថ្លៃលើកូតាសំលៀកបំពាក់ ដែលត្រូវបាននាំចេញទៅកាន់សហរដ្ឋអាមេរិកសំរាប់ឆ្នាំ ២០០៣

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម / ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១:** គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និង ដែលបានចុះបញ្ជីនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ត្រូវបានអញ្ជើញអោយមកដេញថ្លៃតាមប្រភេទផ្សេងៗនៃកូតា ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន។

Prakas on tender quotas thirtheen auctioned 28-02-2003

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288

**ប្រការ ២:** រោងចក្រនីមួយៗត្រូវបានអនុញ្ញាតអោយចូលរួមដេញថ្លៃ ដោយមិនកំណត់បរិមាណកូតា ទៅតាមប្រភេទនីមួយៗ ដូចខាងក្រោមៈ

| Category | Tender Quantity | Quantity per Batch |
|---|---|---|
| 334/634 | 16,073 dozens | មិនកំណត់បរិមាណ |
| 335/635 | 14,659 dozens | មិនកំណត់បរិមាណ |
| 338/339 | 346,181 doznes | មិនកំណត់បរិមាណ |
| 340/640 | 235,446 dozens | មិនកំណត់បរិមាណ |
| 347/348/647/648 | 357,015 dozens | មិនកំណត់បរិមាណ |
| 352/652 | 99,323 dozens | មិនកំណត់បរិមាណ |
| 435 | 8,176 dozens | មិនកំណត់បរិមាណ |
| 438 | 12,694 dozens | មិនកំណត់បរិមាណ |
| 445/446 | 48,743 dozens | មិនកំណត់បរិមាណ |
| 638/639 | 202,035 dozens | មិនកំណត់បរិមាណ |
| 645/646 | 134,965 dozens | មិនកំណត់បរិមាណ |

**ប្រការ ៣:** ពាក្យដេញថ្លៃនីមួយៗត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រ ដែលមានការបញ្ជាក់ពីធនាគារ " Certified Check" ដែលមានតម្លៃ ស្មើនឹង ១០ % នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រ នេះត្រូវទូទាត់ជូនគណៈកម្មការគ្រប់គ្រងកូតានាំចេញ (EQMC) ។ ការបង់ប្រាក់កក់ អប្បបរមាមិនគ្រប់ចំនួន ១០ % នៃតំលៃសរុប ឬ មូលប្បទានប័ត្រមិនបានបញ្ជាក់ពីធនាគារ នឹងត្រូវចាត់ទុកជា ពាក្យសុំដេញថ្លៃដែលមិនគ្រប់លក្ខណៈសម្បត្តិ ចូលរួមដេញថ្លៃ ។

ឧទាហរណ៍ : រោងចក្រ A ដេញថ្លៃ

២០.០០០ ឡូ តំលៃ ៨ ដុល្លា ក្នុងមួយឡូ= ១៦០.០០០ ដុល្លា

សរុប ១៦០.០០០ ដុល្លា

ប្រាក់កក់ ១០ % គឺ ១៦.០០០ ដុល្លា ។

**ប្រការ ៤ :** ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាមប្រភេទកូតានីមួយៗ នឹងត្រូវចាត់ទុកថា ជាការដេញថ្លៃដែលបានទទួលជ័យជំនះ ។ បរិមាណកូតានឹងត្រូវបានបែងចែក ជូនអ្នកដេញថ្លៃម្នាក់ៗ ដែលបានទទួលជោគជ័យ រហូតដល់បរិមាណកូតាសរុប ត្រូវបានបែងចែកអស់ជាស្ថាពរ ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288

**ប្រការ ៥ :** កូតាដែលមិនទាន់បែងចែក នឹងបន្តទុកសំរាប់ការដេញថ្លៃលើកក្រោយទៀត ។

**ប្រការ ៦ :** តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវទទួលយក ចំពោះរាល់ការបន្ថែមចំនួន ទសភាគ 20 សេន (Twenty Cent ) ដុល្លាអាមេរិក លើថ្លៃឯកត្តា ។

| Category | Minimum Bid | Category | Minimum Bid |
|---|---|---|---|
| 334/634 | US$ 2.00 | 435 | US$ 0.40 |
| 335/635 | US$ 2.00 | 438 | US$ 1.00 |
| 338/339 | US$ 2.00 | 445/446 | US$ 0.40 |
| 340/640 | US$ 1.00 | 638/639 | US$ 1.00 |
| 347/348/647/648 | US$ 3.00 | 645/646 | US$ 0.40 |
| 352/652 | US$ 0.40 | | |

**ប្រការ ៧ :** ពាក្យសុំដេញថ្លៃត្រូវដាក់ជូន ប្រធានគណៈកម្មការគ្រប់គ្រងកូតានាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម, ដែលមានទីតាំង នៅអាគារលេខ ២០A ជាន់ទី២, មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន ១០% នៃតំលៃដេញថ្លៃសរុប ពីខាងក្នុងស្រោមសំបុត្រនោះ សំរាប់ជាការផ្ទៀងផ្ទាត់ ។

**ប្រការ ៨ :** កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៣ វេលាម៉ោង ៨:០០ ព្រឹក នៅទីស្តីការក្រសួងពាណិជ្ជកម្ម អាគារលេខ ២០A ជាន់ទី២ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ។

**ប្រការ ៩ :** កាលបរិច្ឆេទឈប់ទទួលពាក្យសុំដេញថ្លៃ ត្រូវកំណត់នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ វេលាម៉ោង ៥:០០ ល្ងាច ។

**ប្រការ ១០:** លទ្ធផលនៃការដេញថ្លៃនឹងត្រូវប្រកាសជាសាធារណៈ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម នៅរសៀលថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៣ ។

**ប្រការ ១១:** អ្នកចូលរួមដេញថ្លៃដែលបានទទួលជោគជ័យ នឹងអាចទទួលយកកូតារបស់ខ្លួនទៅប្រើប្រាស់បាន បន្ទាប់ពីបានទូទាត់តំលៃដេញថ្លៃដែលនៅសេសសល់រួច ។ កាលកំណត់នៃការទូទាត់ចុងក្រោយ គឺកំណត់ត្រឹមថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៣ ។



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213283
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com

**ប្រការ ១២ :** អ្នកចូលរួមដេញថ្លៃដែលបានទទួលជោគជ័យ ហើយខកខានមិនបានទទួលយក បរិមាណកូតារបស់ខ្លួន នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៣ ទេ នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតាដែលមិនបានទទួលយកនោះត្រូវបន្តទុកសំរាប់ការដេញថ្លៃលើកក្រោយ ។ ក្រសួងពាណិជ្ជកម្ម រក្សាសិទ្ធិមិនអនុញ្ញាតឱ្យក្រុមហ៊ុននោះ ចូលរួមដេញថ្លៃ លើកក្រោយៗទៀតឡើយ ។

**ប្រការ ១៣ :** អ្នកចូលរួមដេញថ្លៃដែលមិនបានទទួលជោគជ័យ នឹងត្រូវផ្តល់ជូនវិញភ្លាមនូវប្រាក់កក់ ១០% របស់ខ្លួន ។

**ប្រការ ១៤ :** កូតាដែលទទួលបានតាមរយៈការដេញថ្លៃនេះ នឹងត្រូវបានប្រើប្រាស់សំរាប់តែឆ្នាំសារពើពន្ធ ២០០៣ ប៉ុណ្ណោះ ដោយផ្អែកតាមកិច្ចព្រមព្រៀងវាយនភ័ណ្ឌ រវាងសហរដ្ឋអាមេរិក និងកម្ពុជា នាចុងឆ្នាំ ២០០១ ។

**ប្រការ ១៥ :** សេចក្តីសំរេចរបស់គណៈកម្មការគ្រប់គ្រងកូតានាំចេញ នៅក្នុងការអនុវត្តការដេញថ្លៃនេះ គឺជាការសំរេចចុងក្រោយ ។

**ប្រការ ១៦ :** នាយកខុទ្ទកាល័យ, អគ្គនាយកបច្ចេកទេស, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានរដ្ឋបាល, ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតានាំចេញ ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម_ប្រសិទ្ធ**

**ចំលងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- រាជកិច្ច
- ទូរទស្សន៍ជាតិ, វិទ្យុជាតិ និង កាសែតជាតិ "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

Prakas on tender quotas thirtheen auctioned 28-02-2003